ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ០០៩ MOC / SM 2011

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 009
Date: 26-01-11. Time: 12:00
For : GMAC

# ប្រកាស

## ស្តីពី

## ការកែសម្រួលនីតិវិធីក្នុងការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ ១៧៦ MOC/SM ២០០៦ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦ ស្តីពីវិធានការចំបាច់ មួយចំនួនសម្រាប់គ្រប់គ្រងការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

-យោងស្មារតីអង្គប្រជុំក្រុមការងារកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៩ និងកិច្ចប្រជុំថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១០

## សម្រេច

**<u>ប្រការ ១:</u>** អនុញ្ញាតឱ្យនាយកដ្ឋានពាក់ព័ន្ធ និងតំណាងរបស់ក្រសួងពាណិជ្ជកម្ម នៅតំបន់សេដ្ឋកិច្ចពិសេសនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម (C/O) ជូនអ្នកនាំចេញសម្លៀកបំពាក់ដោយដាក់ បញ្ចូលក្នុងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមតែមួយ នូវសម្លៀកបំពាក់ប្រភេទខុសគ្នា (Different Categories) ដែលស្ថិតក្នុងឈុតជាមួយគ្នា ដូចមានចែងលម្អិតក្នុងប្រការ ៣ នៃសេចក្តីប្រកាសលេខ ១៧៦ MOC/SM 2006 ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦ របស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២:** អនុញ្ញាតអោយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងតំណាងរបស់ក្រសួងពាណិជ្ជកម្មនៅតំបន់សេដ្ឋកិច្ចពិសេសនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ដាក់បញ្ចូលក្នុងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម (C/O) តែមួយនូវផលិតផលបន្ទាប់បន្សំ (Accessories) ដែលផលិតនៅប្រទេសផ្សេង ហើយចាំបាច់ត្រូវភ្ជាប់ជាមួយនឹងសម្លៀកបំពាក់ជាឈុតផលិតនៅកម្ពុជាដោយបញ្ជាក់អោយច្បាស់នូវប្រភពដើម នៃផលិតផលបន្ទាប់បន្សំ (Accessories) នោះ ។

**ប្រការ ៣:** កាតព្វកិច្ចបង់កម្រៃគ្រប់គ្រងការនាំចេញជូនរដ្ឋ ត្រូវគោរពតាមខ្លឹមសារនៃសេចក្តីប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលការកំណត់កម្រៃគ្រប់គ្រងការនាំចេញដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤:** នាយិកាខុទ្ទកាល័យ អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី ប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគី ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- សមាគមរោងចក្រកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា
- គ្រប់តំបន់សេដ្ឋកិច្ចពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា
- គ្រប់រោងចក្រផលិត និង កែច្នៃសំរាប់នាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
  "ដើម្បីសហការអនុវត្តន៍"
- ដូចក្នុងប្រការ ៤
- ឯកសារ-កាលប្បវត្តិ